## សិទ្ធិរបស់អ្នកជំងឺ

អ្នកមានសិទ្ធិ៖

1. ចំពោះការថែទាំដែលមានការគិតគូរ និងការគោរព និងមានភាពងាយស្រួល។ អ្នកមានសិទ្ធិចំពោះការគោរពវប្បធម៌ចិត្តសាស្ត្រ សាសនាគុណតម្លៃផ្ទាល់ខ្លួនជំនឿ និងចំណង់ចំណូលចិត្តរបស់អ្នក។
2. មានសមាជិកគ្រួសារ (ឬអ្នកតំណាងផ្សេងទៀតពីការជ្រើសរើសរបស់អ្នក) និងគ្រូពេទ្យផ្ទាល់ខ្លួនរបស់អ្នកទទួលបានការជូនដំណឹងភ្លាមៗអំពីការចូលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរបស់អ្នក។
3. ស្គាល់ឈ្មោះរបស់គ្រូពេទ្យថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណដែលប្រតិបត្តិនៅក្នុងវិសាលភាពនៃអាជ្ញាប័ណ្ណវិជ្ជាជីវៈរបស់គាត់ដែលមានទំនួលខុសត្រូវចម្បងលើការសម្របសម្រួលការថែទាំរបស់អ្នក និងឈ្មោះព្រមទាំងទំនាក់ទំនងវិជ្ជាជីវៈរបស់គ្រូពេទ្យឬអ្នកដែលមិនមែនជាគ្រូពេទ្យដែលនឹងជួបអ្នក។
4. ទទួលបានព័ត៌មានអំពីស្ថានភាពសុខភាពការរោគវិនិច្ឆ័យបុរេនិម្មិតវគ្គនៃការព្យាបាលទស្សនៈចំពោះការជាសះស្បើយ និងលទ្ធផលនៃការថែទាំរបស់អ្នក (រួមទាំងលទ្ធផលដែលមិនអាចស្មានទុកមុន) នៅក្នុងលក្ខខណ្ឌដែលអ្នកអាចយល់។

   អ្នកមានសិទ្ធិទទួលបានកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក។ អ្នកនឹងទទួលបាន“សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាព”ដាច់ដោយឡែកដែលរៀបរាប់អំពីសិទ្ធិរបស់អ្នកក្នុងការទទួលបានកំណត់ត្រារបស់អ្នក។
   អ្នកមានសិទ្ធិចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធិភាព និងចូលរួមនៅក្នុងការអភិវឌ្ឍ និងការអនុវត្តនៃគម្រោងថែទាំរបស់អ្នក។ អ្នកមានសិទ្ធិចូលរួមនៅក្នុងសំណួរប្រកបដោយសីលធម៌ដែលលើកឡើងនៅក្នុងវគ្គថែទាំរបស់អ្នករួមទាំងបញ្ហានៃការដោះស្រាយវិវាទការមិនព្រមទទួលសេវាកម្មសង្គ្រោះបន្ទាន់ និងការបញ្ឈប់ឬការដកហូតការព្យាបាលសង្គ្រោះបឋម។
5. ធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការថែទាំសុខភាព និងទទួលព័ត៌មានអំពីការព្យាបាល ឬនីតិវិធីវះកាត់ណាមួយដែលបានដាក់ស្នើឲ្យបានច្រើនតាមដែលអ្នកត្រូវការដើម្បីផ្តល់ការព្រមព្រៀងជាព័ត៌មាន ឬដើម្បីបដិសេធវគ្គព្យាបាល។ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់ព័ត៌មាននេះត្រូវរួមបញ្ចូលការពណ៌នាអំពីនីតិវិធីវះកាត់ ឬការព្យាបាលហានិភ័យសំខាន់ៗផ្នែកវេជ្ជសាស្ត្រដែលពាក់ព័ន្ធវគ្គជំនួសនៃការព្យាបាលឬមិនមែនការព្យាបាល និងហានិភ័យពាក់ព័ន្ធនីមួយៗ និងឈ្មោះរបស់បុគ្គលដែលនឹងអនុវត្តនីតិវិធីវះកាត់ឬការព្យាបាល។
6. ស្នើសុំឬបដិសេធការព្យាបាលទៅតាមទំហំដែលបានអនុញ្ញាតដោយច្បាប់។ ប៉ុន្តែអ្នកមិនមានសិទ្ធិទាមទារការព្យាបាល ឬសេវាកម្មសមរម្យឬដែលមិនចាំបាច់វេជ្ជសាស្ត្រឡើយ។ អ្នកមានសិទ្ធិចាកចេញពីកន្លែងផ្តល់សេវាសុខភាព បើទោះបីជាប្រឆាំងទៅនឹងការណែនាំរបស់សមាជិកនៃបុគ្គលិកពេទ្យក៏ដោយទៅតាមទំហំដែលបានអនុញ្ញាតដោយច្បាប់។
7. ទទួលបានការណែនាំប្រសិនបើកន្លែងផ្តល់សេវាសុខភាព/គ្រូពេទ្យថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណដែលប្រតិបត្តិនៅក្នុងវិសាលភាពនៃអាជ្ញាប័ណ្ណវិជ្ជាជីវៈរបស់គាត់ស្នើសុំចូលរួមឬធ្វើការពិសោធន៍ទៅលើមនុស្សដែលប៉ះពាល់ដល់ការថែទាំ ឬការព្យាបាលរបស់អ្នក។ អ្នកមានសិទ្ធិក្នុងការបដិសេធចូលរួមនៅក្នុងគម្រោងសិក្សាស្រាវជ្រាវបែបនេះបាន។
8. ការឆ្លើយតបដែលសមហេតុផលទៅនឹងសំណើដែលសមហេតុផលណាមួយត្រូវបានធ្វើឡើងសម្រាប់សេវាកម្ម។
9. ការវាយតម្លៃ និងការគ្រប់គ្រងការឈឺចាប់របស់អ្នកដោយសមរម្យព័ត៌មានអំពីការឈឺចាប់វិធានការបំបាត់ការឈឺចាប់ និងចូលរួមនៅក្នុងការសម្រេចចិត្តលើការគ្រប់គ្រងការឈឺចាប់។ អ្នកអាចស្នើសុំឬបដិសេធការប្រើប្រាស់រាល់បែបបទណាមួយ ឬទាំងអស់នៅក្នុងការបំបាត់ការឈឺចាប់រួមទាំងថ្នាំដែលមានជាតិអាភៀនប្រសិនបើអ្នក រងការឈឺចាប់ដែលពុំអាចព្យាបាលបានរ៉ាំរ៉ៃខ្លាំងធ្ងន់ធ្ងរ។
   វេជ្ជបណ្ឌិតអាចនឹងបដិសេធក្នុងការចេញវេជ្ជបញ្ជាថ្នាំដែលមានជាតិអាភៀនប៉ុន្តែបើដូច្នោះមែន នោះត្រូវតែជូនដំណឹងដល់អ្នកថាមានគ្រូពេទ្យដែលមានឯកទេសក្នុងការព្យាបាលការឈឺចាប់ដោយប្រើវិធីសាស្ត្រដែលរួមបញ្ចូលការប្រើប្រាស់ជាតិអាភៀន។
10. ការសរសេរសំបុត្របណ្តាំពេលនៅរស់។ នេះរួមទាំងការចាត់តាំងអ្នកធ្វើការសម្រេចចិត្តប្រសិនបើអ្នកអសមត្ថភាពក្នុងការយល់ដឹងអំពីការព្យាបាលដែលបានស្នើឬមិនអាចប្រាស្រ័យទាក់ទងពីបំណងប្រាថ្នារបស់អ្នកពាក់ព័ន្ធនឹងការថែទាំ។ បុគ្គលិកកន្លែងផ្តល់សេវាសុខភាព និងគ្រូពេទ្យដែលផ្តល់ការថែទាំនៅក្នុងកន្លែងនោះត្រូវអនុវត្តតាមបណ្តាំពេលនៅរស់ទាំងនេះ។ សិទ្ធិរបស់អ្នកជំងឺទាំងអស់អនុវត្តចំពោះអ្នកដែលទទួលខុសត្រូវស្របច្បាប់ដើម្បីធ្វើការសម្រេចចិត្តពាក់ព័ន្ធទៅនឹងការថែទាំសុខភាពក្នុងនាមអ្នក។ បណ្តឹងអំពីលក្ខខណ្ឌតម្រូវនៃសំបុត្របណ្តាំពេលនៅរស់អាចធ្វើឡើងបានទៅក្រសួងសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ា (California Department of Public Health) (សូមមើលព័ត៌មានទំនាក់ទំនងខាងក្រោម)។
11. ត្រូវគោរពឯកជនភាពផ្ទាល់ខ្លួន។ ការពិភាក្សាករណីប្រឹក្សាយោបល់ការពិនិត្យសុខភាព និងការព្យាបាលគឺជាការសម្ងាត់ ហើយគួរតែធ្វើឡើងដោយមានការប្រុងប្រយ័ត្ន។ អ្នកមានសិទ្ធិដឹងពីមូលហេតុសម្រាប់វត្តមានរបស់បុគ្គលទាំងឡាយបាន។ អ្នកមានសិទ្ធិឲ្យអ្នកកំដរចាកចេញមុនពេលចាប់ផ្តើមការពិនិត្យ និងនៅពេលដែលកំពុងពិភាក្សាអំពីបញ្ហានៃការព្យាបាល។ វាំងននឯកជនភាពនឹងត្រូវបានប្រើប្រាស់នៅក្នុងបន្ទប់ពាក់កណ្តាលឯកជន។
12. ការធ្វើការប្រាស្រ័យទាក់ទង និងកំណត់ត្រាទាំងអស់ប្រកបដោយការសម្ងាត់ដែលទាក់ទងនឹងការថែទាំ និងការស្នាក់របស់អ្នកនៅក្នុងកន្លែងផ្តល់សេវាសុខភាព។ អ្នកនឹងទទួលបាន“សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាព” ដាច់ដោយឡែកដែលរៀបរាប់អំពីសិទ្ធិឯកជនភាពរបស់អ្នកយ៉ាងលម្អិត និងរបៀបដែលយើងអាចនឹងប្រើប្រាស់ និងបញ្ចេញព័ត៌មានសុខភាពដែលមានការការពាររបស់អ្នក។

13. ទទួលបានការថែទាំនៅក្នុងបរិយាកាសដែលមានសុវត្ថិភាពគ្មានការរំលោភបំពានផ្លូវចិត្តផ្លូវកាយផ្លូវភេទឬពាក្យសំដី និងការមិនយកចិត្តទុកដាក់ការកេងប្រវ័ញ្ចឬការបៀតបៀន។ អ្នកមានសិទ្ធិទទួលបានសេវាការពារ និងគាំពារ រួមទាំងការជូនដំណឹងដល់ភ្នាក់ងាររដ្ឋាភិបាលអំពីការមិនយកចិត្តទុកដាក់ឬការរំលោភបំពាន។
14. គ្មានការបង្ខាំងទុក និងភាពនៅដាច់ពីគេនៃទម្រង់ណាមួយដែលត្រូវបានប្រើជាមធ្យោបាយបង្ខិតបង្ខំដាក់វិន័យ ភាពងាយស្រួលឬការសងសឹកដោយបុគ្គលិក។
15. ការបន្តការថែទាំដោយសមហេតុផល និងដឹងពីពេលវេលា និងទីកន្លែងណាត់ជួបជាមុនព្រមទាំងអត្តសញ្ញាណរបស់បុគ្គលដែលផ្តល់ការថែទាំនោះ។
16. ទទួលបានការជូនដំណឹងពីគ្រូពេទ្យឬប្រតិភូគ្រូពេទ្យអំពីការបន្តលក្ខខណ្ឌតម្រូវ និងជម្រើសនៃការថែទាំសុខភាពបន្ទាប់ពីចាកចេញពីកន្លែងផ្តល់សេវាសុខភាព។ អ្នកមានសិទ្ធិចូលរួមក្នុងការបង្កើត និងការអនុវត្តផែនការចាកចេញរបស់អ្នក។ តាមការស្នើសុំរបស់អ្នកមិត្តភក្តិឬសមាជិកគ្រួសារក៏អាចនឹងទទួលបានព័ត៌មាននេះផងដែរ។
17. ដឹងពីច្បាប់ និងគោលការណ៍របស់កន្លែងផ្តល់សេវាសុខភាពដែលអនុវត្តចំពោះអាកប្បកិរិយារបស់អ្នកក្នុងអំឡុងពេលជាអ្នកជំងឺ។
18. ចាត់តាំងអ្នកជួយព្រមទាំងអ្នកកំដរដែលអ្នកជ្រើសរើសប្រសិនបើអ្នកមានសមត្ថភាពធ្វើការសម្រេចចិត្ត ថាតើអ្នកកំដរមានទំនាក់ទំនងជាប់សាច់ឈាមអាពាហ៍ពិពាហ៍ឬស្ថានភាពដៃគូគ្រួសារដែលបានចុះបញ្ជីឬអត់លុះត្រាតែះ មិនអនុញ្ញាតឱ្យមានអ្នកកំដរ។ កន្លែងផ្តល់សេវាសុខភាពកំណត់យ៉ាងសមហេតុផលថាវត្តមានរបស់អ្នកកំដរណាម្នាក់នឹងបង្កគ្រោះថ្នាក់ដល់សុខភាពឬសុវត្ថិភាពរបស់អ្នកជំងឺសមាជិកនៃបុគ្គលិកកន្លែងផ្តល់សេវាសុខភាពឬអ្នកកំដរផ្សេងទៀតចំពោះកន្លែងផ្តល់សេវាសុខភាពឬនឹងបង្កការរំខានដល់ប្រតិបត្តិការ របស់កន្លែងផ្តល់សេវាសុខភាពយ៉ាងធ្ងន់ធ្ងរ។ អ្នកបានប្រាប់បុគ្គលិកកន្លែងផ្តល់សេវាសុខភាពថាអ្នកលែងចង់ឱ្យបុគ្គលណាម្នាក់មកសួរសុខទុក្ខទៀតហើយ។ ប៉ុន្តែកន្លែងផ្តល់សេវាសុខភាពអាចនឹងបង្កើតការរឹតត្បិតដែលសមហេតុផល នៅពេលការមកសួរសុខទុក្ខរួមទាំងការរឹតត្បិតលើម៉ោងសួរសុខទុក្ខ និងចំនួនអ្នកកំដរផងដែរ។ កន្លែងផ្តល់សេវាសុខភាពត្រូវតែជូនដំណឹងដល់អ្នក (ឬអ្នកជួយរបស់អ្នកតាមការសមរម្យ) អំពីសិទ្ធិសួរសុខទុក្ខរបស់អ្នក

រួមទាំងការរឹតត្បិតឬដែនកំណត់នៃការព្យាបាលទាំងឡាយ។ កន្លែងផ្តល់សេវាសុខភាពមិនអនុញ្ញាតឱ្យរឹតត្បិតកំណត់ឬបដិសេធឯកសិទ្ធិសួរសុខទុក្ខផ្សេងទៀតដោយផ្អែកលើជាតិសាសន៍ពណ៌សម្បុរដើមកំណើតជាតិសាសនាភេទ អត្តសញ្ញាណយេនឌ័រនិន្នាការផ្លូវភេទឬពិការភាពឡើយ។
19. ពិចារណាពីបំណងប្រាថ្នារបស់អ្នកថាតើអ្នកខ្វះសមត្ថភាពធ្វើការសម្រេចចិត្ត ក្នុងគោលបំណងដើម្បីកំណត់ថានរណាខ្លះអាចមកសួរសុខទុក្ខបាន។ វិធីសាស្ត្រនៃការពិចារណានោះនឹងអនុលោមតាមច្បាប់សហព័ន្ធហើយត្រូវបានបង្ហាញនៅក្នុងគោលការណ៍របស់កន្លែងផ្តល់សេវាសុខភាពស្តីពីការ សួរសុខទុក្ខ។ យ៉ាងហោចណាស់កន្លែងផ្តល់សេវាសុខភាពត្រូវរាប់បញ្ចូលបុគ្គលដែលរស់នៅក្នុងគ្រួសាររបស់អ្នក និងអ្នកជួយណាម្នាក់ដោយយោងតាមច្បាប់សហព័ន្ធ។
20. ពិនិត្យ និងទទួលបានការពន្យល់អំពីវិក្កយបត្ររបស់អ្នកដោយមិនគិតពីប្រភពនៃការទូទាត់ប្រាក់។ មូលដ្ឋានទិន្នន័យនៃការទូទាត់ប្រាក់ដោយបើកចំហរ (Open Payments) គឺជាឧបករណ៍របស់សហព័ន្ធមួយដែលប្រើ

ដើម្បីស្វែងរកការទូទាត់ប្រាក់ដែលធ្វើឡើងដោយក្រុមហ៊ុនឱសថ និងឧបករណ៍ទៅដល់គ្រូពេទ្យ និងមន្ទីរពេទ្យសម្រាប់ការបង្រៀន។ វាអាចរកឃើញបាននៅ openpaymentsdata.cms.gov។ ”
21. អនុវត្តសិទ្ធិទាំងនេះដោយមិនគិតពី និងគ្មានការរើសអើងដោយផ្អែកលើភេទស្ថានភាពសេដ្ឋកិច្ចប្រវត្តិសិក្សាជាតិសាសន៍ពណ៌សម្បុរសាសនាពូជពង្សដើមកំណើតជាតិនិន្នាការផ្លូវភេទអត្តសញ្ញាណ/លក្ខណៈយេនឌ័រពិការភាពស្ថានភាពសុខភាព ស្ថានភាពគ្រួសារអាយុស្ថានភាពដៃគូគ្រួសារដែលបានចុះបញ្ជីព័ត៌មានហ្សែនសញ្ជាតិភាសាចម្បងស្ថានភាពអន្តោប្រវេសន៍ (លើកលែងតែតម្រូវដោយច្បាប់សហព័ន្ធ) ឬប្រភពនៃការទូទាត់ប្រាក់សម្រាប់ការថែទាំ។
22. ដាក់បណ្តឹងសារទុក្ខ។ ប្រសិនបើអ្នកចង់ដាក់បណ្តឹងសារទុក្ខទៅកន្លែងផ្តល់សេវាសុខភាពនេះអ្នកអាចធ្វើដូច្នេះបានដោយសរសេរជាលាយលក្ខណ៍អក្សរឬតាមការហៅទូរសព្ទទៅផ្នែកទំនាក់ទំនងអ្នកជំងឺ/ផ្នែកគាំពារអ្នកជំងឺ (Patient Relation Department/Patient Advocate)។ បណ្តឹងសារទុក្ខរបស់អ្នកនឹងត្រូវបានត្រួតពិនិត្យ

ហើយអ្នកនឹងទទួលបានការឆ្លើយតបជាលាយលក្ខណ៍អក្សរ។ ការឆ្លើយតបជាលាយលក្ខណ៍អក្សរនឹងមានឈ្មោះបុគ្គលដែលត្រូវទាក់ទងនៅកន្លែងផ្តល់សេវាសុខភាព វិធានការដែលបានអនុវត្តដើម្បីស៊ើបអង្កេតបណ្តឹងសារទុក្ខលទ្ធផលនៃដំណើរការបណ្តឹងសារទុក្ខ និងកាលបរិច្ឆេទនៃការបញ្ចប់ដំណើរបណ្តឹងសារទុក្ខ។ កង្វល់ទាក់ទងនឹងគុណភាពនៃការថែទាំឬការឆាប់ចាកចេញពីមន្ទីរពេទ្យក៏នឹងត្រូវបញ្ជូនទៅអង្គការត្រួតពិនិត្យការប្រើប្រាស់ និងគ្រប់គ្រងគុណភាពដោយក្រុមការងារ (Peer Review Organization, PRO)

តាមដែលអាចធ្វើបាន។

23. ដាក់បណ្តឹងទៅក្រសួងសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ាដោយមិនគិតថាអ្នកប្រើប្រាស់ដំណើរការបណ្តឹងសារទុក្ខរបស់កន្លែងផ្តល់សេវាសុខភាពឬអត់នោះទេ។ លេខទូរសព្ទ និងអាសយដ្ឋានរបស់ក្រសួងសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ាគឺ 800-228-5234,681SParkerSt.,Suite200Orange,CA92868។
24. ដាក់បណ្តឹងទៅក្រសួងការងារ និងលំនៅឋានសមរម្យ (Department of Fair Employment and Housing, DFEH) តាម www.dfeh.ca.gov,800-884-1684ឬ800-700-2320 (TTY) ឬ2218KausenDr.,#100, ElkGrove, CA95758។

PATIENT HIM LABEL

NAME

DOB

FIN#

MR#

SEX on ID

APPROVED FOR USE AT ALL DHS / DPH FACILITIES
SCAN INTO ELECTRONIC HEALTH RECORD